**NGO-CEDAW និង CAMBOW**

# បង្ហាញពីក្ដីកង្វល់អំពីការប៉ះពាល់ដល់ឯករាជ្យភាពនៃប្រព័ន្ធតុលាការ

យោងតាមការវិវឌ្ឍន៍ថ្មីៗនៃការអនុម័តច្បាប់ចំនួនបី រួមមាន៖

១. ច្បាប់ស្ដីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
២. ច្បាប់ស្ដីពី ការរៀបចំអង្គការតុលាការ
៣. ច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

NGO-CEDAW និង CAMBOW អំពាវនាវយ៉ាងទទូចដល់ក្រុមប្រឹក្សាធម្មនុញ្ញ សូមលោកមេត្តាពិនិត្យលើមាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា បានចែងយ៉ាងច្បាស់អំពីសារៈសំខាន់នៃឯករាជ្យភាពរបស់តុលាការ "...អំណាចតុលាការ គឺជាអំណាចឯករាជ្យ..."។[1] តាមខ្លឹមសារនៃមាត្រានេះ បង្ហាញថា ច្បាប់ដែលបានស្នើទាំងបីនេះ ដោយផ្ទាល់ គឺផ្ទុយពីរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងនេះអាចនឹងប៉ះពាល់ដល់ឯករាជ្យភាពនៃស្ថានប័នតុលាការ។

យើងខ្ញុំសង្ឃឹមថា នៅក្នុងដំណើរការពិនិត្យទៅលើធម្មនុញ្ញភាពនៃច្បាប់ទាំងបី ដែលត្រូវបានអនុម័តរួចដោយរដ្ឋសភា និងព្រឹទ្ធសភានោះ ក្រុមប្រឹក្សាធម្មនុញ្ញនឹង "...មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ..."[2] ហើយយើងខ្ញុំមានជំនឿថា នឹងមានការច្រានចោលច្បាប់ទាំងបីនេះ ដោយសារច្បាប់ទាំងនេះមិនអាចធានាឯករាជ្យភាពរបស់តុលាការបានទេ។

ភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:


កញ្ញា អ៊ុំ ទេពផល្លីន (NGO-CEDAW) ទូរស័ព្ទ: ០១១ ៩៨៤ ៨៨៣/០៩៨ ៩៨៤ ៨៨៣ Email: phallin@cfswf.org
លោក សម អន (NGO-CEDAW) លេខទូរស័ព្ទ: ០១៥ ៧៧០ ១២០ Email: orn_idea@yahoo.com
លោកស្រី ចឹម ចាន់នាង (NGO-CEDAW) លេខទូរស័ព្ទ: ០១២ ៦៦ ៨៨ ៥៣ Email: ngocedaw.pnh@gmail.com
កញ្ញា នៅ ស្រីអូន (CAMBOW) លេខទូរស័ព្ទ: ០៧៧ ៧២២ ៧២៥ Email: cambowmail@gmail.com


[1] មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា

[2] មាត្រា ១៣៦ នៃរដ្ឋធម្មនុញ្ញកម្ពុជា